**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តតាកែវ**

-សំណុំរឿងព្រហ្មទណ្ឌលេខ៖ ១០៧១
ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២៣
-សាលក្រមព្រហ្មទណ្ឌលេខ៖ ១៦ "ញ"
ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៤

# សាលក្រម

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តតាកែវ

បានបើកសវនាការជាសាធារណៈនៅសាលាដំបូងខេត្តតាកែវ នាថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៤ វេលាម៉ោង ៣ និង ៣០នាទីរសៀល ដោយមានសមាសភាពចូលរួមដូចតទៅ:

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

លោកស្រី [redacted] ចៅក្រម នៃសាលាដំបូងខេត្តតាកែវ

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ចៅក្រម នៃសាលាដំបូងខេត្តតាកែវ

លោកស្រី [redacted] ចៅក្រម នៃសាលាដំបូងខេត្តតាកែវ

**តំណាងអយ្យការ**

លោកស្រី [redacted] ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងខេត្តតាកែវ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជី នៃសាលាដំបូងខេត្តតាកែវ

**ដើម្បីជំនុំជម្រះ**

លើសំណុំរឿងព្រហ្មទណ្ឌលេខ៖ ១០៧១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២៣ ដែលមានជនជាប់ចោទ៖

១-ឈ្មោះ [redacted] **ចាន់ដារ៉ា ហៅ ដូ** ភេទប្រុស អាយុ២០ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរដឹកជញ្ជូនទំនិញក្រុមហ៊ុន Grab មានទីកន្លែងកំណើត និងទីលំនៅមុនពេលឃាត់ខ្លួននៅភូមិ[redacted] ខេត្តតាកែវ ឪពុកឈ្មោះ [redacted] **ឃ្លោក** (រស់) ម្តាយឈ្មោះ [redacted] **ស្រី** (រស់) មានប្រពន្ធឈ្មោះ [redacted] **លីហ្សា** (រស់) មានកូន ០១នាក់ ជានីតិជន កម្រិតវប្បធម៌រៀនថ្នាក់ទី០៦ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ៖ គ្មាន។ (ឃុំខ្លួនថ្ងៃទី០៥-១០-២០២៣)

២-ឈ្មោះ [redacted] **និត ហៅ ជីវ័ន្ត** ភេទប្រុស អាយុ២៤ឆ្នាំ សញ្ជាតិខ្មែរ ជនជាតិខ្មែរ មុខរបរជាងផ្សារដែក មានទីកន្លែងកំណើត និងទីលំនៅមុនពេលឃាត់ខ្លួននៅភូ[redacted] ខេត្តកំពង់ចាម ឪពុកឈ្មោះ [redacted] **តា** (រស់) ម្តាយឈ្មោះ [redacted] **នាង** (រស់) នៅលីវ ជានីតិជន កម្រិតវប្បធម៌រៀនថ្នាក់ទី ០៦ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ៖ គ្មាន។ (ឃុំខ្លួនថ្ងៃទី០៥-១០-២០២៣)



Scanned with CamScanner

ជាប់ចោទពីបទៈ **លួចមានស្ថានទម្ងន់ទោស (ឆក់កាបូប)** ប្រព្រឹត្តនៅភូមិចំការដៀប ឃុំអង្គតាសោម ស្រុកត្រាំកក់ ខេត្តតាកែវ កាលពីថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២៣ បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

ដោយមានលោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សារុន** ភេទស្រី អាយុ៤៣ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបររអាជីវករ មានទីលំនៅស្ថិតនៅភូមិអង្គរជ័យ ឃុំដំណាក់កន្ទួត ស្រុកកំពង់ត្រាច ខេត្តកំពត។

-បានឃើញ ពាក្យបណ្តឹងចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២៣ របស់ឈ្មោះ [redacted] **សារុន** ។

-បានឃើញ របាយការណ៍សរុបលេខៈ ៨១/០២៣ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២៣ របស់ស្នងការនគរបាលខេត្តតាកែវ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខៈ ៨៦០ ដ.ស.ព/២៣ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ របស់តំណាងអយ្យការអមសាលាដំបូងខេត្តតាកែវ។

-បានឃើញ ដីកាដំណោះស្រាយលេខៈ ៧៧៥ (ឈ)/២០២៣ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តតាកែវ។

-បានឃើញ ដីកាចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះលេខៈ ៨៧៤ ដចត/២៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២៣ របស់ប្រធានសាលាដំបូងខេត្តតាកែវ។

-បានឃើញឯកសារផ្សេងៗក្នុងសំណុំរឿងព្រហ្មទណ្ឌខាងលើ។

## អង្គហេតុដែលប្តឹងមកតុលាការមានដូចតទៅៈ

កាលពីថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២៣ វេលាម៉ោង៦ និង ៣០នាទីព្រឹក ជនត្រូវចោទឈ្មោះ [redacted] **ចាន់ដារ៉ា ហៅដូ** ភេទប្រុស អាយុ២០ឆ្នាំ និងឈ្មោះ [redacted] **និត ហៅជីវ័ន្ត** ភេទប្រុស អាយុ២៤ឆ្នាំ បានជិះម៉ូតូ ០១គ្រឿងម៉ាកហុងដាឌ្រីមស ១២៥ ស៊េរីឆ្នាំ២០២៣ ពាក់ស្លាកលេខ ភ្នំពេញ 1HJ-3556 ធ្វើសកម្មភាពឆក់កាបូបរបស់ជនរងគ្រោះឈ្មោះ [redacted] **សារុន** ភេទស្រី អាយុ៤៣ឆ្នាំ នៅលើចំណុចផ្លូវជាតិលេខ៣ ស្ថិតក្នុងភូមិចំការដៀប ឃុំអង្គតាសោម ស្រុកត្រាំកក់ ខេត្តតាកែវ បណ្តាលឱ្យជនរងគ្រោះដួលរងរបួសស្រាល ហើយត្រូវបានសមត្ថកិច្ចឃាត់ខ្លួនជនត្រូវចោទទាំង ០២នាក់ខាងលើ និងបានកសាងសំណុំរឿងបញ្ជូនមកតុលាការដើម្បីចាត់ការតាមនីតិវិធីច្បាប់តែម្តង។

## នាពេលសវនាការ

-ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **ចាន់ដារ៉ា ហៅ ដូ** បានឆ្លើយថាៈ ចំពោះរឿងហេតុដែលចោទប្រកាន់នេះ គឺខ្ញុំពិតជាបានប្រព្រឹត្តពិតមែន ដោយកាលពីថ្ងៃទី០៤ ខែតុលា ឆ្នាំ ២០២៣ វេលាម៉ោង ៥ និង ០០នាទី ខ្ញុំបាទ និងមិត្តភក្តិឈ្មោះ [redacted] និត បានជិះម៉ូតូ ១គ្រឿងម៉ាកហុងដាឌ្រីមស៊េរីឆ្នាំ២០២៣ ពាក់ស្លាកលេខ ភ្នំពេញ 1KJ-3556 ចេញពីភ្នំពេញដើម្បីទៅដើរលេងនៅរំលេច ខេត្តកំពត ពេលជិះមកដល់ខាងត្បូងផ្សារអង្គតាសោម ក៏បានឃើញមានមនុស្សស្រីម្នាក់ជិះម៉ូតូស្របទិសគ្នានឹងម៉ូតូរបស់ខ្ញុំ ហើយឃើញមានស្ពាយកាបូបលុយ និងគិតថាជាឱកាស និងទំនងផងនោះ ពេលនោះខ្លួនបានសហការឱ្យមិត្តភក្តិរបស់ខ្ញុំឈ្មោះ [redacted] និត អែបម៉ូតូជិតស្ត្រីម្នាក់នោះ ហើយខ្លួនក៏ឆក់កាបូបរបស់គាត់តែឆក់មិនបានសម្រេចបណ្តាលឱ្យជនរងគ្រោះដួលម៉ូតូ តែមិនឃើញមានរបួសអ្វីនោះទេ។



Scanned with CamScanner

បន្ទាប់មកពួកខ្ញុំបាទបានជិះម៉ូតូគេចខ្លួនសំដៅទៅភ្នំពេញវិញ ពេលជិះទៅដល់ខាងជើងផ្សារអង្គតាសោមក៏មានប្រជាពលរដ្ឋ និងសមត្ថកិច្ចចាប់ឃាត់ខ្លួនពួកតែម្តង។

-ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **និត ហៅ ជីវ័ន្ត** បានឆ្លើយថា៖ ចំពោះរឿងហេតុដែលចោទប្រកាន់នេះ គឺពួកខ្ញុំពិតជាបានប្រព្រឹត្តពិតមែន ដោយកាលពីថ្ងៃកើតហេតុនៅពេលព្រឹកខ្ញុំបាទបានខ្ចីម៉ូតូ ១គ្រឿងម៉ាកហុងដាឌ្រីមសេរីឆ្នាំ២០២៣ ពាក់ស្លាកលេខ ភ្នំពេញ1KJ-3556 ពីមិត្តភក្តិរបស់ខ្ញុំដែលមានឈ្មោះ **វីត** ហើយខ្លួនបានឌុបមិត្តភក្តិរបស់ខ្ញុំឈ្មោះ [redacted] **ចាន់ដារ៉ា** ចេញពីភ្នំពេញតាមផ្លូវជាតិលេខ ៣ទៅដើរលេងនៅម៉ុំរំលេច ខេត្តកំពត ពេលជិះមកដល់ម្តុំខាងត្បូងផ្សារអង្គតាសោមក៏បានឃើញមនុស្សស្រីម្នាក់ជិះម៉ូតូស្របទិសគ្នាមានស្ពាយកាបូបលុយនៅចំហៀង និងឃើញថាមានឱកាសល្អផង ខ្ញុំបាទក៏បាននិយាយគ្នាជាមួយមិត្តភក្តិខ្ញុំឈ្មោះ [redacted] ចាន់ដារ៉ា បន្ទាប់មកខ្ញុំបាទបានអែបម៉ូតូជិតម៉ូតូស្ត្រីម្នាក់នោះ ហើយឈ្មោះ [redacted] ចាន់ដារ៉ា បានឆក់កាបូបរបស់គាត់ តែឆក់មិនបានសម្រេច បណ្តាលឱ្យជនរងគ្រោះដួលម៉ូតូ តែមិនមានរបួសនោះទេ បន្ទាប់មកពួកខ្ញុំបាទបានជិះម៉ូតូគេចខ្លួនសំដៅទៅភ្នំពេញវិញ ពេលជិះបានចម្ងាយនៅខាងជើងផ្សារអង្គតាសោមក៏ត្រូវបានសមត្ថកិច្ចចាប់ឃាត់ខ្លួនតែម្តង។ ខ្ញុំបាទធ្លាប់ធ្វើសកម្មភាពឆក់ចំនួន ២ដងមកហើយតែមិនដែលបង្កឱ្យជនរងគ្រោះមានរបួសនោះទេ។

-អំណានចម្លើយរបស់ជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សារុន** បានឆ្លើយថា៖ នៅថ្ងៃទី ៤ ខែតុលា ឆ្នាំ២០២៣ វេលាម៉ោង ៦ និង ៣៧នាទី ខ្លួនបានជិះម៉ូតូចេញពីផ្សារអង្គតាសោមតាមផ្លូវជាតិលេខ៣ ពីជើងទៅត្បូង ពេលមកដល់ចំនុចចន្លោះបង្គោលគីឡូម៉ែត្រលេខ ៧៦-៧៧ ស្ថិតក្នុងភូមិចំការដៀប ឃុំអង្គតាសោម ស្រុកត្រាំកក់ ខេត្តតាកែវ ស្រាប់តែមានម៉ូតូ ១គ្រឿងម៉ាកហុងដាឌ្រីមសេរីឆ្នាំ២០២៣ ពាក់ស្លាកលេខ ភ្នំពេញ1KJ-3556 ជិះគ្នាចំនួន២នាក់បានជិះម៉ូតូមកក្បែរម៉ូតូរបស់ខ្លួន ហើយធ្វើសកម្មភាពឆក់កាបូបរបស់ខ្លួនតែឆក់មិនបានបណ្តាលឱ្យខ្លួនដួលម៉ូតូរងរបួសពេញខ្លួន ហើយពួកវាបានជិះម៉ូតូគេចខ្លួន។ នៅក្នុងរឿងនេះខ្លួនសូមទាមទារសំណងជំងឺចិត្តចំនួន ២០លានរៀល និងស្នើសុំដល់តុលាការសម្រេចផ្តន្ទាទោសលើជនជាប់ចោទតាមច្បាប់។

-ជនជាប់ចោទឈ្មោះ [redacted] **ចាន់ដារ៉ា ហៅ ដូ** បានធ្វើសេចក្តីកត់សម្គាល់ខ្លីៗថា៖ មូលហេតុដែលខ្ញុំឆក់នោះ គឺដោយសារតែពួកខ្ញុំអត់មានលុយជិះទៅដើរលេង និងណាមួយឃើញថាជនរងគ្រោះស្ពាយកាបូបទំនងផងក៏បានឆក់តែម្តងទៅ។

-ជនជាប់ចោទឈ្មោះ [redacted] **និត ហៅ ជីវ័ន្ត** បានធ្វើសេចក្តីកត់សម្គាល់ខ្លីៗថា៖ ខ្ញុំបាទធ្លាប់ធ្វើសកម្មភាពឆក់ចំនួន ២ដងមកហើយ។ ក្នុងរឿងនេះខ្ញុំបាទដឹងកំហុសហើយៗខ្ញុំនឹងពុំធ្វើរឿងនេះនៅពេលក្រោយៗទៀតហើយ។

-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា៖ ក្រោយពីបានសួរដេញដោល និងស្តាប់ចម្លើយសារភាពរបស់ជនជាប់ចោទទាំងពីរនាក់ ក៏ដូចជាអំណានចម្លើយរបស់ជនរងគ្រោះ ព្រមទាំងភស្តុតាងនានាដែលមានក្នុងសំណុំរឿង គឺតំណាងអយ្យការនៅតែតម្កល់ការចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរទុកជាបានការដដែល ដោយសុំឱ្យផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] **ចាន់ដារ៉ា ហៅ ដូ** និងឈ្មោះ [redacted] **និត ហៅ ជីវ័ន្ត** ពីបទ៖ **លួចមានស្ថានទម្ងន់ទោស (ឆក់កាបូប)** បទល្មើស

ដែលមានថែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌដដែល និងសុំដល់តុលាការសម្រេចតាមច្បាប់។

-លោក [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **ចាន់ដារ៉ា ហៅ ដូ** និងឈ្មោះ [redacted] **និត ហៅ ជីវ័ន្ត** បានធ្វើសេចក្តីសន្និដ្ឋានការពារកូនក្តីខ្លួនថា៖ ឆ្លងតាមការសួរដេញដោលនៅក្នុងអង្គសវនាការនេះឃើញថាកូនក្តីខ្ញុំឈ្មោះ [redacted] **ចាន់ដារ៉ា ហៅ ដូ** និងឈ្មោះ [redacted] **និត ហៅ ជីវ័ន្ត** បានឆ្លើយសារភាពថា៖ ចំពោះរឿងហេតុនេះ គឺខ្លួនពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ពិតមែន។ ហើយឃើញថាកូនក្តីខ្ញុំបាទបានឆ្លើយនៅពេលនេះ គឺបានសារភាពគ្រប់បែបយ៉ាង និងពុំបង្កការស្មុគស្មាញដល់តុលាការនោះទេ។ ហេតុដូច្នេះក្នុងនាមខ្ញុំបាទជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **ចាន់ដារ៉ា ហៅ ដូ** និងឈ្មោះ [redacted] **និត ហៅ ជីវ័ន្ត** គឺសូមស្នើសុំដល់តុលាការសម្រេចពិចារណាក្នុងការផ្តន្ទាទោសលើកូនក្តីខ្ញុំបាទ និងមេត្តាបន្ធូរបន្ថយទោសដល់កូនក្តីខ្ញុំបាទផង និងចំពោះការប្តឹងទាមទារសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណីនោះ គឺខ្ញុំសូមស្នើសុំដល់តុលាការមេត្តាពិចារណាត្រង់ចំណុចនេះ។

-លោក [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **ចាន់ដារ៉ា ហៅ ដូ** និងឈ្មោះ [redacted] **និត ហៅ ជីវ័ន្ត** បានធ្វើសេចក្តីសន្និដ្ឋានការពារកូនក្តីខ្លួនថា៖ ឃើញថានៅក្នុងអង្គសវនាការនេះកូនក្តីខ្ញុំបាទបានឆ្លើយសារភាពនូវកំហុសរបស់ពួកខ្លួនហើយ ដោយគាត់មានការភ្ញាក់រឭក និងសហការក្នុងការផ្តល់ចម្លើយជូនតុលាការទៀតផង ព្រមទាំងមានការសោកស្តាយចំពោះអំពើដែលបានប្រព្រឹត្តផង។ ហេតុនេះក្នុងនាមខ្ញុំបាទជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទសូមស្នើសុំដល់តុលាការមេត្តាសម្រេចបន្ធូរបន្ថយទោសដល់កូនក្តីខ្ញុំបាទផង។

-សម្តីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] **ចាន់ដារ៉ា ហៅ ដូ** ថា៖ ខ្ញុំបាទសំណូមពរដល់តុលាការមេត្តាបន្ធូរបន្ថយទោស និងសម្រាលទោសដល់រូបខ្ញុំផង ព្រោះខ្ញុំបានដឹងពីកំហុសហើយ និងសន្យាថាពេលចេញពីពន្ធនាគារវិញឈប់ប្រព្រឹត្តអំពើនេះបន្តទៀតហើយ និងធ្វើជាពលរដ្ឋល្អនៅក្នុងសង្គម។

-សម្តីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] **និត ហៅ ជីវ័ន្ត** ថា៖ ខ្ញុំបាទសំណូមពរដល់តុលាការមេត្តាបន្ធូរបន្ថយទោស និងសម្រាលទោសដល់រូបខ្ញុំផង ព្រោះខ្ញុំបានដឹងពីកំហុសហើយ និងសន្យាថាពេលចេញពីពន្ធនាគារវិញឈប់ប្រព្រឹត្តអំពើនេះបន្តទៀតហើយ និងធ្វើជាពលរដ្ឋល្អនៅក្នុងសង្គម។

-**ក្រោយពីបាន** ស្តាប់ចម្លើយសារភាពរបស់ជនជាប់ចោទ។

-**ក្រោយពីបាន** ស្តាប់អំណានចម្លើយរបស់ជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណី។

-**ក្រោយពីបាន** ពិនិត្យឯកសារ និងភស្តុតាងពាក់ព័ន្ធក្នុងសំណុំរឿង។

-**ក្រោយពីបាន** ស្តាប់សេចក្តីកត់សម្គាល់ខ្លីៗរបស់ជនជាប់ចោទ។

-**ក្រោយពីបាន** ស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ ។

-**ក្រោយពីបាន** ស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

-**ក្រោយពីបាន** ស្តាប់សំណូមពរចុងក្រោយរបស់ជនជាប់ចោទ។

-**ក្រោយពីបាន** ពិភាក្សាសម្ងាត់ជាមួយនឹងក្រុមប្រឹក្សាជំនុំជម្រះរួចហើយ។



Scanned with CamScanner

-**ក្រោយពីបាន** ពិចារណាត្រឹមត្រូវតាមច្បាប់រួចរាល់ហើយ ។

**សំអាងហេតុ**

១-ក្រោយពីធ្វើការស៊ើបសួរតាមនីតិវិធីចប់សព្វគ្រប់ហើយ ចៅក្រមស៊ើបសួរបានចេញដីកាដំណោះស្រាយលេខ៖ ៧៧៥ (ឈ)/២០២៣ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៣ ដោយបានសម្រេចបញ្ជូនជនត្រូវចោទឈ្មោះ [redacted] **ចាន់ដារ៉ា ហៅ ដូ** ភេទប្រុស អាយុ២០ឆ្នាំ និងឈ្មោះ [redacted] **និត ហៅ ជីវ័ន្ត** ភេទប្រុស អាយុ២៤ឆ្នាំ មកជំនុំជម្រះពីបទ៖ **លួចមានស្ថានទម្ងន់ទោស (ឆក់កាបូប)** ប្រព្រឹត្តនៅភូមិចំការជៀប ឃុំអង្គតាសោម ស្រុកត្រាំកក់ ខេត្តតាកែវ កាលពីថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២៣ បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

២-តាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] **ចាន់ដារ៉ា ហៅ ដូ** និងឈ្មោះ [redacted] **និត ហៅ ជីវ័ន្ត** ព្រមទាំងអំណានចម្លើយបំភ្លឺរបស់ជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សារុន** បញ្ជាក់ឱ្យឃើញថា៖ កាលពីថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២៣ វេលាម៉ោង ៦ និង ៣០នាទីព្រឹក នៅលើចំណុចផ្លូវជាតិលេខ៣ ស្ថិតក្នុងភូមិចំការជៀប ឃុំអង្គតាសោម ស្រុកត្រាំកក់ ខេត្តតាកែវ ពិតជាមានករណីលួចមានស្ថានទម្ងន់ទោស (ឆក់កាបូប) មួយបានកើតឡើងដែលបង្កដោយជនជាប់ចោទឈ្មោះ [redacted] **ចាន់ដារ៉ា ហៅដូ** និងឈ្មោះ [redacted] **និត ហៅជីវ័ន្ត** ដោយបានធ្វើសកម្មភាពឆក់កាបូបរបស់ជនរងគ្រោះឈ្មោះ [redacted] **សារុន** ពិតប្រាកដមែន។ ក្រោយកើតហេតុសមត្ថកិច្ចឃាត់ខ្លួនជនត្រូវចោទទាំង ០២នាក់ខាងលើ និងបានកសាងសំណុំរឿងបញ្ជូនមកតុលាការដើម្បីចាត់ការតាមនីតិវិធីច្បាប់តែម្តង។

៣-យល់ឃើញថា៖ អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] **ចាន់ដារ៉ា ហៅដូ** និងឈ្មោះ [redacted] **និត ហៅជីវ័ន្ត** ដែលបាននាំគ្នាជិះម៉ូតូទៅធ្វើសកម្មភាពឆក់កាបូបរបស់ជនរងគ្រោះឈ្មោះ [redacted] **សារុន** ដើម្បីយកមកធ្វើជាប្រយោជន៍របស់ខ្លួន ដោយចេតនាទុច្ចរិត គឺជាអំពើដែលធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ និងសន្តិសុខសង្គមជាពិសេស គឺបានដកហូតយកនូវទ្រព្យសម្បត្តិស្របច្បាប់របស់អ្នកដទៃទៀតផង ហើយអំពើនេះទៀតសោតត្រូវបានច្បាប់ហាមឃាត់ និងកំណត់ថាជាបទ៖ **លួចមានស្ថានទម្ងន់ទោស (ឆក់កាបូប)** បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

៤-យល់ឃើញថា៖ ជនជាប់ចោទឈ្មោះ [redacted] **ចាន់ដារ៉ា ហៅ ដូ** ភេទប្រុស អាយុ២០ឆ្នាំ និងឈ្មោះ [redacted] **និត ហៅ ជីវ័ន្ត** ភេទប្រុស អាយុ២៤ឆ្នាំ គឺជានីតិជនដែលមានស្មារតីយល់ដឹង និងមានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសព្រហ្មទណ្ឌដែលកើតចេញពីអំពើដែលខ្លួនបានប្រព្រឹត្ត។

៥-យល់ឃើញថា៖ មានធាតុផ្សំបទល្មើសគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] **ចាន់ដារ៉ា ហៅ ដូ** ភេទប្រុស អាយុ២០ឆ្នាំ និងឈ្មោះ [redacted] **និត ហៅ ជីវ័ន្ត** ភេទប្រុស អាយុ២៤ឆ្នាំ ពីបទ៖ **លួចមានស្ថានទម្ងន់ទោស (ឆក់កាបូប)** ប្រព្រឹត្តនៅភូមិចំការជៀប ឃុំអង្គតាសោម ស្រុកត្រាំកក់ ខេត្តតាកែវ កាលពីថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២៣ បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

៦-តាមការប្តឹងសុំរបស់តំណាងអយ្យការដោយសុំឱ្យតុលាការផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] **ចាន់ដារ៉ា ហៅ ដូ** និងឈ្មោះ [redacted] **និត ហៅ ជីវ័ន្ត** ភេទប្រុស អាយុ២៤ឆ្នាំ ពីបទ៖ **លួចមាន**



Scanned with CamScanner

**ស្ថានទម្ងន់ទោស (ឆក់កាបូប)** បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។ តុលាការយល់ឃើញថាការប្តឹងសុំនេះមានមូលដ្ឋានតាមផ្លូវច្បាប់គ្រប់គ្រាន់គប្បីសម្រេចតាមការប្តឹងសុំនេះ។

៧-តាមសេចក្តីសន្និដ្ឋានសុំរបស់លោក [redacted] **កុសល** និងលោក [redacted] **វិច្ឆិកា** ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **ចាន់ដារ៉ា ហៅ ដូ** និងឈ្មោះ [redacted] **និត ហៅ ជីវ័ន្ត** ដោយសំណូមពរដល់ក្រុមប្រឹក្សាជំនុំជម្រះបន្ធូរបន្ថយទោសដល់កូនក្តីខ្លួនដោយសំអាងថាកូនក្តីខ្លួនមានការភ្ញាក់រឭឆ្លើយសារភាពចំពោះតុលាការ និងមានការសោកស្តាយចំពោះអំពើដែលខ្លួនបានប្រព្រឹត្តផងដែរ។ តុលាការយល់ឃើញថា៖ ការស្នើសុំនេះមានមូលដ្ឋាន និងមានហេតុផលសមរម្យ។ ហេតុនេះគប្បីតុលាការសម្រេចពិចារណាសម្រេចតាមច្បាប់។

៨-យល់ឃើញថា៖ នាពេលសវនាការជនជាប់ចោទឈ្មោះ [redacted] **ចាន់ដារ៉ា ហៅ ដូ** និងឈ្មោះ [redacted] **និត ហៅ ជីវ័ន្ត** បានឆ្លើយសារភាពចំពោះអំពើដែលពួកខ្លួនបានប្រព្រឹត្ត ហើយម្យ៉ាងឃើញថាជនជាប់ចោទទាំងពីរនាក់នេះមានការសិក្សា និងរៀនសូត្របានតិចតួច ខ្វះការពិចារណាគ្រប់គ្រាន់។ ហេតុដូច្នេះគប្បីតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារលើជនជាប់ចោទទាំងពីរនាក់នេះក្នុងម្នាក់ៗកំណត់ចំនួន **០៣ (បី) ឆ្នាំ**។

៩-យល់ឃើញថា៖ ជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សារុន** បានប្តឹងទាមទារទាមទារសំណងការខូចខាតពីជនជាប់ចោទឈ្មោះ [redacted] **ចាន់ដារ៉ា ហៅ ដូ** និងឈ្មោះ [redacted] **និត ហៅ ជីវ័ន្ត** សរុបចំនួន ២០.០០០.០០០ (ម្ភៃលាន) រៀល ក៏ប៉ុន្តែឃើញថាដើមបណ្តឹងពុំបានដាក់ភស្តុតាងជូនតុលាការពិនិត្យឱ្យឃើញអំពីទំហំនៃការខូចខាតរបស់ខ្លួនជាក់លាក់នោះទេ។ ហេតុនេះគប្បីតុលាការពិចារណា និងសម្រេចអំពីសំណងនេះ។

១០-ឃើញថា៖ ជនជាប់ចោទឈ្មោះ [redacted] **និត ហៅ ជីវ័ន្ត** បានឆ្លើយថានៅថ្ងៃកើតហេតុរូបខ្លួនបានខ្ចីម៉ូតូ ០១គ្រឿងម៉ាកហុងដាឌ្រីមសេរីឆ្នាំ២០២៣ ពាក់ស្លាកលេខ ភ្នំពេញ1KJ-3556 ដែលជារបស់មិត្តភក្តិខ្លួនឈ្មោះ **វីត** ដើម្បីយកទៅដើរលេង ហើយក៏បានធ្វើសកម្មភាពលួចឆក់កាបូបគេតែម្តង ក្រោយមកសមត្ថកិច្ចក៏បានឃាត់រូបខ្លួន និងឈ្មោះ [redacted] **ចាន់ដារ៉ា ហៅ ដូ** ព្រមទាំងដកហូតបាននូវម៉ូតូខាងលើនេះផងដែរ។ ក្នុងករណីនេះតុលាការយល់ឃើញថា៖ ដោយផ្អែកលើលិខិតទិញ និងលក់ម៉ូតូលេខ៖ ០០២៦០០ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៣, បង្កាន់ដៃទទួល និងតម្កល់ទ្រព្យធានាចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៣ និងកិច្ចសន្យាកម្ចីបង់រំលស់លេខ៖ ០១-២១៤៣៨៦ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៣ ក៏ដូចជាលិខិតបញ្ជាក់លេខ៖ ១៣៥/២៤ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៤ ដែលចេញដោយប៉ុស្តិ៍នគរបាលរដ្ឋបាលខ្វាវ ស្រុកសំរោង ខេត្តតាកែវ ឃើញថា៖ ម៉ូតូ ០១គ្រឿងម៉ាកហុងដាឌ្រីម C125 សេរីឆ្នាំ២០២៣ ពាក់ស្លាកលេខ ភ្នំពេញ1KJ-3556 មានលេខតួ ០០០៥០៧២ និងលេខម៉ាស៊ីន ០០០៥០៧២ ពិតជាកម្មសិទ្ធិរបស់ឈ្មោះ [redacted] **ដាវីត** ភេទប្រុស កើតថ្ងៃទី២៣ ខែមីនា ឆ្នាំ២០០០ មានទីលំនៅស្ថិតនៅភូមិកកោះ ឃុំខ្វាវ ស្រុកទ្រាំង ខេត្តតាកែវ ប្រាកដមែន។ ហេតុនេះគប្បីតុលាការសម្រេចប្រគល់វត្ថុចាប់យកនេះឱ្យទៅម្ចាស់ដើមវិញតាមបញ្ញត្តិមាត្រា ៣៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។



Scanned with CamScanner

## ហេតុដូច្នេះសម្រេច

១-ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] **ចាន់ដារ៉ា ហៅ ដូ** ភេទប្រុស អាយុ២០ឆ្នាំ (អត្តសញ្ញាណខាងលើ) ដាក់ពន្ធនាគារកំណត់ចំនួន **០៣ (បី) ឆ្នាំ** ពីបទៈ **លួចមានស្ថានទម្ងន់ទោស (ឆក់កាបូប)** ប្រព្រឹត្តនៅភូមិចំការជៀប ឃុំអង្គតាសោម ស្រុកត្រាំកក់ ខេត្តតាកែវ កាលពីថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២៣ បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

២-ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] **និត ហៅ ជីវ័ន្ត** ភេទប្រុស អាយុ២៤ឆ្នាំ (អត្តសញ្ញាណខាងលើ) ដាក់ពន្ធនាគារកំណត់ចំនួន **០៣ (បី) ឆ្នាំ** ពីបទៈ **លួចមានស្ថានទម្ងន់ទោស (ឆក់កាបូប)** ប្រព្រឹត្តនៅភូមិចំការជៀប ឃុំអង្គតាសោម ស្រុកត្រាំកក់ ខេត្តតាកែវ កាលពីថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២៣ បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

៣-បង្គាប់ឱ្យជនជាប់ចោទឈ្មោះ [redacted] **ចាន់ដារ៉ា ហៅ ដូ** ភេទប្រុស អាយុ២០ឆ្នាំ និងឈ្មោះ [redacted] **និត ហៅ ជីវ័ន្ត** ភេទប្រុស អាយុ២៤ឆ្នាំ រួមគ្នាសងសំណងការខូចខាតឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សារុន** ភេទស្រី អាយុ៤៣ឆ្នាំ សរុបចំនួន **៤.០០០.០០០ (បួនលាន) រៀល** ការទាមទារលើសពីនេះត្រូវច្រានចោល។

៤-ប្រគល់ម៉ូតូចំនួន ០១គ្រឿងម៉ាកហុងដាឌ្រីម C125 ស៊េរីឆ្នាំ២០២៣ ពាក់ស្លាកលេខភ្នំពេញ1KJ-3556 មានលេខតួ ០០០៥០៧២ និងលេខម៉ាស៊ីន ០០០៥០៧២ ឱ្យទៅឈ្មោះ [redacted] **ដាវីត** ភេទប្រុស កើតថ្ងៃទី២៣ ខែមីនា ឆ្នាំ២០០០ មានទីលំនៅស្ថិតនៅភូមិកកោះ ឃុំខ្វាវ ស្រុកទ្រាំង ខេត្តតាកែវ ដែលជាម្ចាស់ដើមវិញ។

-សាលក្រមនេះជំនុំជម្រះជាសាធារណៈនាថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៤ និងប្រកាសជាសាធារណៈនៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៤ នៅសាលាដំបូងខេត្តតាកែវ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] **ចាន់ដារ៉ា ហៅ ដូ** និងឈ្មោះ [redacted] **និត ហៅ ជីវ័ន្ត** និងកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ **សេក សារុន** ។

-ទុកសិទ្ធិឱ្យប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់៕

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សា** |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |

[redacted]

(បានថតចម្លងត្រឹមត្រូវតាមលិខិតដើម)

ថ្ងៃពុធ ២កើត ខែចេត្រ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

តាកែវ,ថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៤

**ក្រឡាបញ្ជីសវនាការ**

[redacted]

បានឃើញ

តាកែវ,ថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៤

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]



Scanned with CamScanner